# សុន្ទរកថា
# របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
# នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
# ក្នុងពិធីបិទសន្និបាតប្រចាំឆ្នាំរបស់
# ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
# និង ពិធីប្រកាសជាផ្លូវការនៃការធ្វើជាម្ចាស់ផ្ទះរៀបចំ
# កិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី១៣ ឆ្នាំ២០២០

---------------------------

*សម្តេច ឯកឧត្តម លោកជំទាវ*
*ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត*
*អស់លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ជាទីរាប់អាន!*

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយក្រៃលែង ដោយបានមកចូលរួមក្នុងពិធីបិទសន្និបាតប្រចាំឆ្នាំរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការ-អន្តរជាតិ និងការប្រកាសជាផ្លូវការនៃការធ្វើជាម្ចាស់ផ្ទះរបស់កម្ពុជា រៀបចំកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី១៣ ឆ្នាំ២០២០នេះ នៅរាជធានីភ្នំពេញ ។

ខ្ញុំសូមស្វាគមន៍វត្តមានរបស់សម្តេច ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំសមាជិករាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ស្ថាប័នសិក្សាស្រាវជ្រាវ និងសារព័ត៌មាន ជាពិសេសឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត និងអង្គទូតប្រចាំកម្ពុជា ក្នុងពិធីដ៏សំខាន់នេះ ។

ខ្ញុំសូមវាយតំលៃខ្ពស់ ចំពោះរបាយការណ៍សង្ខេបរបស់ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការ-អន្តរជាតិ និងសូមកោតសរសើរចំពោះសមិទ្ធផលសំខាន់ៗជាច្រើន ដែលថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិករបស់ក្រសួងការបរទេសសម្រេចបានក្នុងឆ្នាំកន្លងទៅ ក្នុងការបំពេញបេសកកម្មការទូតដ៏ស្វិតស្វាញ ខណៈដែលពិភពលោកកំពុងឆ្លងកាត់ដំណាក់កាលនៃការប្រែប្រួលដ៏ជ្រាលជ្រៅ មិនប្រាកដប្រជា និងស្មុគស្មាញ។

*សម្តេច ឯកឧត្តម លោកជំទាវ*
*អស់លោក លោកស្រី*

ក្នុងរយៈពេល២ថ្ងៃកន្លងទៅនេះ អង្គសន្និបាតបានពិភាក្សាផ្លាស់ប្ដូរយោបល់លើប្រធានបទក្ដៅៗជាច្រើននៃពិភពលោក និងតំបន់ នាំមកនូវព័ត៌មាន ការវិភាគ និងការវាយតំលៃទៅលើសភាពការណ៍តំបន់នានា ដែលអ្នកការទូតរបស់យើងបំពេញបេសកកម្ម។ អង្គសន្និបាតក៏បានពិភាក្សាគ្នាផងដែរ អំពីបញ្ហាផ្ទៃក្នុងក្រសួង អំពីទំនាក់ទំនងដ៏ស្អិតរមួតរវាងក្រសួងនិងស្ថានបេសកកម្មយើងនានានៅលើសកលលោក និងអំពីការលំបាកនិងការប្រឈមនានាពេលបច្ចុប្បន្ន និងតទៅមុខ។

ថ្ងៃនេះ ខ្ញុំនឹងយកប្រធានបទធំ៣ មកវិភាគ វាយតំលៃ និងណែនាំ ដូចតទៅ៖

**ទី១) <u>អំពីពិភពលោកយើង</u>**

ជាច្រើនឆ្នាំមកហើយ យើងបានរស់នៅក្នុងពិភពលោកមួយដែលកំពុងមានការប្រែប្រួលយ៉ាងជ្រាលជ្រៅនិងស្មុគស្មាញ ជាពិភពលោកមួយដែលកំពុងស្ថិតក្នុងដំណាក់កាលអន្តរកាល ឆ្ពោះទៅរកប្រព័ន្ធពហុប៉ូលដ៏សាំញ៉ាំ ដែលក្នុងនោះតួអង្គចាស់-ថ្មី រដ្ឋនិងមិនមែនរដ្ឋ កំពុងប្រកួតប្រជែងយ៉ាងតានតឹងដើម្បីគ្រប់គ្រង ចាត់ចែង និងដោះស្រាយកិច្ចការនៃភពផែនដី។

ជាពិភពលោកដែលមានការប្រទង់ប្រទាញដោយការប្រកួតតតាំងគ្នារវាងមហាអំណាចធំៗ ដែលបានប្ដូរភាពជាដៃគូពីមុន មកជាការប្រជែង និងការប្រឆាំងគ្នា។ ក្នុងបរិបទនេះ គ្មាននរណាអាចបដិសេធបានទេថា ការប្រជែងគ្នារវាងមហាអំណាចធំបំផុតទាំងពីរជះឥទ្ធិពល និងប៉ះពាល់ដោយផ្ទាល់ដល់ដំណើរការ និងការតម្រង់ទិសរបស់ពិភពលោក។

ស្ថានភាពនេះបានស្ដែងចេញតាមការសើរើឡើងវិញ នូវរបៀបរបបពិភពលោកបើកចំហរមួយ ដែលត្រូវបានបង្កើតឡើងក្រោយសង្គ្រាមលោកលើកទី២ ហើយដែលទោះជាមិនល្អឥតខ្ចោះក៏ដោយ ក៏បានជួយរក្សាសន្តិភាព និងវិបុលភាពដល់ពិភពលោក អស់រយៈពេលជាង៧០ឆ្នាំមកហើយដែរ។ ក្រោមសណ្ដាប់ធ្នាប់អន្តរជាតិនេះ ស្ថាប័នពហុភាគីជាច្រើន ត្រូវបានបង្កើតឡើងដើម្បីជួយរក្សាសន្តិភាព បញ្ចៀសសង្គ្រាម រក្សានីតិរដ្ឋអន្តរជាតិ និងដោះស្រាយជំលោះនានាតាមការចរចា។

ឥឡូវនេះ របៀបរបបអន្តរជាតិដែលផ្អែកលើច្បាប់ និងប្រព័ន្ធពហុភាគី-និយមនេះកំពុងរងសម្ពាធយ៉ាងធ្ងន់ធ្ងរ។

ត្រង់នេះ ក៏មានការជេញដោលគ្នាច្រើនលើនិយមន័យនៃពាក្យ **"របៀបរបបអន្តរជាតិដែលផ្អែកលើច្បាប់"** មិនខុសពីការជេញដោលគ្នាអំពីពាក្យ **"និយាមអន្តរជាតិ"** ( International Standard ) នោះឡើយ។ ព្រោះថា តើអ្នកណាជាអ្នកបង្កើតនិងកំណត់ស្តង់ដារ និងរបៀបរបបអន្តរជាតិនោះ ហើយតើស្តង់ដារនិងរបៀបរបបនោះ ដាក់ឱ្យអ្នកណាជាអ្នកអនុវត្ត? ពេលខ្លះ អ្នកបង្កើតប្រែក្លាយទៅជាអ្នកបោះបង់ទៅវិញ នៅពេលដែលស្តង់ដាររបៀបរបបនោះលែងផ្តល់ ឬ ប្រែទៅជាផ្ទុយនឹងផលប្រយោជន៍ខ្លួន។

យ៉ាងណាក៏ដោយ ការងាកចេញពីពហុភាគីនិយម ដែលមានន័យស្មើនឹងការបោះបង់ចោល ការទទួលខុសត្រូវជាអន្តរជាតិរបស់ខ្លួននោះ គឺជាមូលដ្ឋានចំបងនៃការរំដើបរំជួលបច្ចុប្បន្ននេះ។ ដើម្បីផលប្រយោជន៍ជាតិ និងផលប្រយោជន៍ខ្លួនឯង មេដឹកនាំប្រទេសខ្លះបានសម្រេចដកខ្លួនចេញពីអង្គការចាត់តាំង និងកិច្ចព្រមព្រៀងអន្តរជាតិសំខាន់ៗជាច្រើនមាន៖ កិច្ចព្រមព្រៀងភាពជាដៃគូអន្តរប៉ាស៊ីហ្វិក(TPP) កិច្ចព្រមព្រៀងទីក្រុង Paris ស្តីពីការប្រែប្រួលអាកាសធាតុ អង្គការUNESCO ផែនការសកម្មភាពគ្រប់ជ្រុងជ្រោយរួមស្តីពីបញ្ហានុយក្លេអ៊ែរនៅអ៊ីរ៉ង់ សន្ធិសញ្ញាស្តីពីកម្លាំងអាវុធនុយក្លេអ៊ែររយៈមធ្យម និងពីក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ជាដើម។

ពាណិជ្ជកម្មសេរី និងយុត្តិធម៌ត្រូវគំរាមដោយរូបភាពថ្មីៗ នៃការគាំពារនិយម។ ជាលទ្ធផល សង្គ្រាមពាណិជ្ជកម្មដែលបានកើតឡើងនោះ បានបង្កភាពមិនច្បាស់លាស់ និងហានិភ័យជាច្រើនដល់សេដ្ឋកិច្ច ពាណិជ្ជកម្ម និងហិរញ្ញវត្ថុតំបន់ និងពិភពលោក។ ទោះបីមានការចុះហត្ថលេខាលើ "ដំណាក់កាលទីមួយ" រវាងមហាអំណាចសេដ្ឋកិច្ចធំបំផុតទាំងពីរនៃពិភពលោកក៏ដោយ ក៏ប្រធានបទធំៗ នៅមិនទាន់បានដោះស្រាយនៅឡើយ តួយ៉ាងការការពារកម្មសិទ្ធិបញ្ញា ការផ្ទេរបច្ចេកវិទ្យា សហគ្រាសរដ្ឋ ការបើកទីផ្សារជាដើម។ សង្គ្រាមពាណិជ្ជកម្ម ក៏បានរាលដាលដល់សង្គ្រាមបច្ចេកវិទ្យា សន្តិសុខ និងការពារជាតិ។

**ទី២) <u>សម្ពាធមកលើប្រព័ន្ធនៃរបៀបរបបដែលផ្អែកលើពហុភាគីនិយម និងច្បាប់អន្តរជាតិនេះ បានប៉ះពាល់បន្តដល់ប្រទេសនានាដែលតូចជាងខ្សោយជាង</u>** ទោះបីក្នុងកំរិតនិងរូបភាពខុសគ្នាក៏ដោយ។

ពិតហើយ កម្ពុជាមានឥទ្ធិពលតិចតួចប៉ុណ្ណោះ ក្នុងការកសាងរបៀបរបបអន្តរជាតិ ប៉ុន្តែមិនមែនបានន័យថា យើងមិនអាចជួយអ្វីបានសោះនោះទេ។

កម្ពុជាបានបង្ហាញទៅសហគមន៍អន្តរជាតិ អំពីតួនាទីកាន់តែសកម្មរបស់ខ្លួន នៅក្នុងកិច្ចការពិភពលោក និងតំបន់ ដោយចូលរួមវិភាគទាននានា ក្នុងបុព្វហេតុសន្តិសុខ សន្តិភាព និងសង្គម តួយ៉ាង ការបំពេញភារកិច្ចជាអនុប្រធានមហាសន្និបាតអង្គការសហប្រជាជាតិ ជាសមាជិក ECOSOC និងអង្គការអន្តរជាតិមួយចំនួនទៀត បញ្ជូនកងកំលាំងរក្សាសន្តិភាព ព្រមទាំងចូលរួមក្នុងការប្រយុទ្ធនឹងការប្រឈមនានានៃពិភពលោក មានការប្រឆាំងនឹងភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែន ការប្រែប្រួលអាកាសធាតុ ជាដើម។

ការរួមវិភាគទានរបស់យើងអាចច្រើនប៉ុណ្ណានោះ ក៏អាស្រ័យលើភាពរឹងមាំរបស់យើងនៅក្នុងប្រទេសដែរ។ នយោបាយក្នុងប្រទេស និងនយោបាយក្រៅប្រទេស គឺជាដៃទាំង២នៃខ្លួនប្រាណតែមួយ ដែលត្រូវការគ្នាទៅវិញទៅមកជួយគ្នា និងបំពេញឱ្យគ្នាទៅវិញទៅមក។ យើងបានឃើញការពិតនេះ ជារូបភាពជាក់ស្តែង តាមរយៈនៃការអនុវត្តនយោបាយ **"អាមេរិកជាចំបង"** (America First) ប៉ុន្មានឆ្នាំចុងក្រោយនេះ។ ការកំណត់នយោបាយក្រៅប្រទេស គឺជាកិច្ចការរកលំនឹងដ៏លំបាករវាងការបំពេញកាតព្វកិច្ច ការទទួលខុសត្រូវជាអន្តរជាតិ និងការការពារផលប្រយោជន៍ជាតិខ្លួនឯង។ ស្ថានភាពនយោបាយ សេដ្ឋកិច្ច សង្គម និងសន្តិសុខក្នុងស្រុក តែងតែជាកត្តាកំណត់ដល់ឥរិយាបថ និងជំហរដែលត្រូវប្រកាន់យកចំពោះស្ថានការណ៍ បញ្ហា ឬសម្ពាធ ណាមួយពីខាងក្រៅ។

យ៉ាងណាមិញ អតីតកាលជូរចត់របស់កម្ពុជាតម្រូវឱ្យប្រទេសយើងខ្ញុំកំណត់យកសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ជាអាទិភាពចំបងបំផុត។ គុណតំលៃទាំងនេះ ពឹងពាក់គ្នាទៅវិញទៅមកផង ហើយអាចគង់វង្សទៅបាន លុះត្រាយើងការពារបាននូវឯករាជ្យ អធិបតេយ្យ និងអព្យាក្រឹត្យជាតិខ្លួនឯងផង។ ជិត៣០ឆ្នាំនៃសង្គ្រាម ទុក្ខវេទនា និងការបំផ្លិចបំផ្លាញនៅប្រទេសយើង មានដើមកំណើតពីការបាត់បង់ឯករាជ្យ អធិបតេយ្យ និងអព្យាក្រឹត្យនៅដើមទសវត្សទី៧០នោះឯង។

ថ្មីៗនេះ យើងក៏បានឃើញនូវភាពអន្តរាយនានា ដែលបានកើតឡើងក្រោយការជ្រៀតជ្រែករបស់មហាអំណាចធំៗ ក្នុងនាមនៃការស្តារលទ្ធិប្រជាធិបតេយ្យ ចូលកិច្ចការផ្ទៃក្នុងរបស់ប្រទេសអធិបតេយ្យដូចគ្នា តែតូចជាងនិងខ្សោយជាងនោះ នៅតំបន់មជ្ឈិមបូព៌ា អាហ្វ្រិក អាមេរិកឡាទីន ឬនៅអាស៊ី។

នយោបាយដាក់ទណ្ឌកម្ម ដែលការពិតជានយោបាយប្រទេសធំសង្កត់ទៅលើប្រទេសតូចជាង មិនមែនជានយោបាយត្រឹមត្រូវទេ ជាពិសេសនៅពេលពួកគេអនុវត្តនយោបាយនេះ ក្នុងនាមគុណតំលៃ និងគោលការណ៍ដែលគេប្រើ ឬមិនប្រើស្របតាមកាលៈទេសៈ និងផលប្រយោជន៍ណាដែលអំណោយផលឱ្យគេ។

ចំពោះកម្ពុជាវិញ សហគមន៍អន្តរជាតិ គប្បីជួយយើងឱ្យបានខ្លាំងឡើង ឯកភាពរឹងមាំឡើង ជាជាងបំបែកបំបាក់ បន្ទុចបង្អាក់ឱ្យចុះខ្សោយតាមវិធានការដែលនឹងអាចក្លាយជាកំហុសលើកទី៣របស់ខ្លួន។ គេគួរណាស់គោរពជម្រើសនយោបាយ សេដ្ឋកិច្ចនិងសង្គមរបស់យើង ពីព្រោះតាំងពីរំដោះប្រទេសជាតិពីរបបប្រល័យពូជសាសន៍មកដល់ពេលនេះ ជម្រើសនោះតែងតែឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងពិតប្រាកដរបស់ប្រទេស និងប្រជាជន។ នោះគឺជាជម្រើសដែលបានស្តារជូនប្រជាជនកម្ពុជាវិញ នូវសិទ្ធិជាមូលដ្ឋានគ្រប់បែបយ៉ាង គឺសិទ្ធិទទួលអាហារ ការថែទាំសុខភាព ការរៀនសូត្រ ជម្រកផ្ទះសំបែង សិទ្ធិការងារ វប្បធម៌ និងសេរីភាព។ ជាងនេះទៀត នោះក៏ជាជម្រើសដែលបានការពារសន្តិភាព សន្តិសុខ ស្ថិរភាព ឯកភាពសង្គម និងបានចៀសវាងកុំឱ្យឯករាជ្យ អធិបតេយ្យជាតិធ្លាក់ទៅក្នុងដៃអ្នកដទៃ និងបំរើផលប្រយោជន៍ ដែលផ្ទុយពីបំណងប្រាថ្នារបស់ប្រជាពលរដ្ឋដ៏ច្រើនលើសលុប។

**ទី៣) <u>ទិសដៅការងារការបរទេស</u>**

ក្នុងបណ្តាឆ្នាំខាងមុខ ភាពតានតឹង ការប្រឈម និងការប្រកួតប្រជែងបច្ចុប្បន្ន នឹងបន្តវិវឌ្ឍក្នុងលក្ខណៈលំបាក ស្មុគស្មាញ ពិបាកប៉ាន់ស្មានបានតាមទិសមិនប្រាកដប្រជាទាំងលើវិស័យនយោបាយ សេដ្ឋកិច្ច យោធា និងសន្តិសុខ។

ភាពតានតឹងនៅតំបន់មួយចំនួន អាចនឹងកើនឡើង និងឈានទៅរកកម្រិតប្រកបដោយគ្រោះថ្នាក់ នៅអាស៊ីខាងត្បូង នៅអាមេរិកឡាទីន និងនៅអាហ្វ្រិកជាដើម ជាពិសេសនៅតំបន់ដែលកំពុងមានភាពផុយស្រួយ។

ការប្រឈមធំៗជាសកល ដូចជាការប្រែប្រួលធាតុអាកាស ភេរវកម្មបញ្ហាជនភៀសខ្លួន ឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឧក្រិដ្ឋកម្មឆ្លងដែនបញ្ហាជំងឺឆ្លង (តួយ៉ាង Corona virus នៅ Wuhan ថ្មីៗនេះ) ។ល។ នឹងនៅតែបន្តចោទជាគ្រោះថ្នាក់ ហើយទាមទារឱ្យមានការប្រឹងប្រែងរួមគ្នាបន្ថែមទៀតដើម្បីរកដំណោះស្រាយឆ្លើយតប។

ការប្រើលេសស្តីពីការលើកស្ទួយលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស តាមស្តង់ដារទ្វេ និងមិនសមស្រប ដើម្បីជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងប្រទេសទីទៃ តាមការប្រើប្រាស់ឧបករណ៍ នយោបាយនិងសេដ្ឋកិច្ច នឹងបន្តដាក់សម្ពាធធ្ងន់ធ្ងរលើប្រទេសទន់ខ្សោយ រាប់ទាំងកម្ពុជាយើងផង ។

ស្ថានការណ៍បែបនេះ តម្រូវឱ្យកម្ពុជាប្រកាន់នយោបាយការបរទេសមួយ ដែលបំរើ លើកស្ទួយ និងការពារផលប្រយោជន៍គោលរបស់ជាតិដោយប្រមូលផ្តុំលើការងារធំទាំង៥ដូចតទៅៈ

__**ការងារទី១ គឺការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី អព្យាក្រឹត្យភាព រក្សាការពារឱ្យបានគត់មត់នូវសន្តិភាព សន្តិសុខ ស្ថិរភាព សណ្តាប់ធ្នាប់ និងឯកភាពសង្គម។**__

សម្រាប់ប្រទេសដែលធ្លាប់ឆ្លងកាត់ទុក្ខលំបាកនៃសង្គ្រាមបំផ្លិចបំផ្លាញ និងការបែកបាក់ដូចកម្ពុជា តើមានអ្វីសំខាន់ជាងនិងមានតំលៃជាងសន្តិភាព ស្ថិរភាព ឯកភាពនិងសុខដុមនីយកម្មនៃសង្គមជាតិនោះ? ពាក្យស្លោក **"អរគុណសន្តិភាព"** ដែលខ្ញុំបានបំផុសដើម្បីអបអរឆ្នាំថ្មីឆ្នាំសកលកន្លងទៅនេះ ត្រូវបានទទួលស្វាគមន៍ពីប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានទាំងអស់ និងក្លាយទៅជាចលនាដ៏ធំមួយក្នុងទូទាំងប្រទេស។ ដោយហេតុនេះ កម្ពុជានឹងបន្តរក្សាយ៉ាងម៉ឺតមាំនូវឯករាជ្យភាពក្នុងរាល់សេចក្តីសម្រេចរបស់យើងលើបន្ទាត់នយោបាយក្នុងនិងក្រៅប្រទេស ទាំងលើវិស័យនយោបាយ សេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ ជាពិសេសក្នុងវិស័យសន្តិសុខ និងការពារជាតិ ដោយគោរពនូវគោលនយោបាយអព្យាក្រឹត្យភាពអចិន្ត្រៃយ៍ មិនចូលបក្សសម្ព័ន្ធ រួមរស់ដោយសន្តិសហវិជ្ជមានជាមួយប្រទេសជិតខាង និងប្រទេសដទៃទៀតទាំងអស់នៅលើសកលលោក និងដោះស្រាយរាល់បញ្ហាដោយសន្តិវិធី និងគោរពផលប្រយោជន៍ផងគ្នាទៅវិញទៅមក។ យើងនឹងរក្សានិងប្រើប្រាស់សិទ្ធិអធិបតេយ្យរបស់ខ្លួន ក្នុងការជ្រើសរើសវិធី និងមធ្យោបាយដែលសមស្របបំផុត ដើម្បីការពារបូរណភាពទឹកដី ការពារផលប្រយោជន៍ស្នូលរបស់ជាតិ ស្របតាមរដ្ឋធម្មនុញ្ញ។

__**ការងារធំទី២ គឺអនុវត្តតាមទិសស្លោក «បង្កើនមិត្តខាងក្រៅ ដោយឈរលើស្មារតីឯករាជ្យជាតិ»។**__ កម្ពុជានឹងខិតខំបន្តពង្រឹងចំណងមិត្តភាព សហប្រតិបត្តិការ ទំនាក់ទនង និងភាពជាដៃគូល្អប្រសើរដែលមានស្រាប់ជាមួយប្រទេសជាមិត្តនានា ស្តារឡើងវិញនូវទំនាក់ទំនងសហប្រតិបត្តិការជាមួយមិត្តចាស់ និង

ស្វែងរកកសាងទំនាក់ទំនងល្អជាមួយមិត្តថ្មី ជាពិសេសនៅអឺរ៉ុបខាងកើត និងកណ្តាល នៅអាស៊ីកណ្តាល នៅអាហ្វ្រិក មជ្ឈិមបូព៌ា និងអាមេរិកឡាទីន។

ជាការពិត ការធ្វើមិត្តជាមួយគ្រប់គ្នា ងាយនិយាយជាងធ្វើឆ្ងាយណាស់។ ជាពិសេសចំពោះប្រទេសតូចដូចកម្ពុជា ដែលសម្ពាធពីខាងក្រៅតែងបង្ខំឱ្យយើងជ្រើសរើសមិត្ត ឬក៏ឱ្យយើងធ្វើជាមិត្តជាមួយប្រទេសនេះ និងយកប្រទេសផ្សេងជាសត្រូវ។ ក៏ប៉ុន្តែ ទោះធ្វើមិត្តជាមួយនរណាក៏ដោយ ក៏មិនមានន័យថាកម្ពុជាបោះបង់ចោលឯករាជ្យ និងអធិបតេយ្យខ្លួននោះទេ។ ក្នុងឋានៈជានាយករដ្ឋមន្ត្រី ខ្ញុំមិនដែលធ្វើសេចក្តីសម្រេចណា ដើម្បីតម្រូវចិត្តប្រទេសណាមួយនោះទេ។ ខ្ញុំមិនធ្វើអ្វីដែលនឹងនាំឱ្យខូចប្រយោជន៍ជាតិ និងប្រជាពលរដ្ឋកម្ពុជានោះឡើយ។

កម្ពុជានឹងរួមចំណែកកាន់តែសំខាន់ថែមទៀត ក្នុងការកសាងសហគមន៍អាស៊ាន ដោយសំដៅបំរើប្រជាជន និងយកប្រជាជនជាស្នូល រក្សានិងពង្រឹងឯកភាព និងមជ្ឈភាពរបស់អាស៊ាន ហើយតាមរយៈអាស៊ាន ជំរុញនិងពង្រឹងទំនាក់ទំនងជាមួយដៃគូខាងក្រៅ ដើម្បីការអភិវឌ្ឍ និងកំណើនសេដ្ឋកិច្ចនិងសង្គម ផ្អែកលើគោលការណ៍គ្រឹះ២គឺៈ ការប្រកាន់កុងសង់ស៊ុសក្នុងរាល់សេចក្តីសម្រេច និងការមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងផងគ្នា។

**ការងារទី៣ គឺជំរុញការងារការទូតសេដ្ឋកិច្ច** ដើម្បីរួមចំណែកជាមួយស្ថានប័នជំនាញក្នុងការទាក់ទាញទុនវិនិយោគពីបរទេស ធ្វើពិពិធកម្មប្រភពវិនិយោគ ពង្រីកទីផ្សារនាំផលិតផលកម្ពុជាទៅក្រៅប្រទេស ទាក់ទាញទេសចរណ៍ និងលើកស្ទួយវប្បធម៌ជាតិលើឆាកអន្តរជាតិ។ រួមចំណែកក្នុងកិច្ចប្រឹងប្រែង ដើម្បីឈានទៅចុះហត្ថលេខាលើកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចតំបន់គ្រប់ជ្រុងជ្រោយ (RCEP) បន្តចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មថ្មី ពិសេសជាមួយចិន សាធារណរដ្ឋកូរ៉េ និងសហភាពសេដ្ឋកិច្ច អឺរ៉ុប-អាស៊ី។

**ការងារទី៤ គឺបន្តគាំទ្រនិងពង្រឹងពហុភាគីនិយម** នៅក្នុងការចាត់ចែងកិច្ចការពិភពលោក និងរួមចំណែកក្នុងកិច្ចប្រឹងប្រែងជាសកលក្នុងការដោះស្រាយបញ្ហា ការប្រឈម និងគ្រោះថ្នាក់នានាដែលគំរាមកំហែងដល់សន្តិភាព សន្តិសុខ របៀបរបបអន្តរជាតិមួយដែលផ្អែកលើច្បាប់ និងការអភិវឌ្ឍប្រកបដោយចីរភាព។

បន្តចូលរួមយ៉ាងសកម្មដល់បុព្វហេតុសន្តិភាពលើពិភពលោកដោយបញ្ជូនកងកំលាំងកម្ពុជាចូលរួមក្នុងបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហ

ប្រជាជាតិ បំពេញភារកិច្ចមនុស្សធម៌ ប្រកបដោយវិជ្ជាជីវៈខ្ពស់ ការគោរពយ៉ាងម៉ឺងម៉ាត់នូវវិន័យនិងច្បាប់អន្តរជាតិ កសាងទំនាក់ទំនងល្អជាមួយអង្គភាព និងប្រជាជនមូលដ្ឋាន។

ការធ្វើឱ្យស៊ីសង្វាក់គ្នា និងការបំពេញឱ្យគ្នាទៅវិញទៅមក នូវគំនិតផ្តួចផ្តើមតំបន់នានា មាន «ខ្សែក្រវ៉ាត់និងផ្លូវ» បណ្តា «យុទ្ធសាស្ត្រឥណ្ឌូ-ប៉ាស៊ីហ្វិក» និងនយោបាយរបស់ប្រទេសធំៗ ក្នុងតំបន់ដែលសម្លឹងមកតំបន់អាស៊ី-អាគ្នេយ៍របស់យើង ក៏ដូចជាកិច្ចសហប្រតិបត្តិការនានា ក្នុងក្របខ័ណ្ឌទន្លេមេគង្គដើម្បីទាញយកផលប្រយោជន៍សម្រាប់ការអភិវឌ្ឍ។

យកចិត្តទុកដាក់ឱ្យកាន់តែខ្ពស់ចំពោះការអភិវឌ្ឍបញ្ញាសិប្បនិមិត និងបច្ចេកវិទ្យាឌីជីថល ដើម្បីតាមឱ្យទាន់ប្រទេសជិតខាង និងពង្រឹងសមត្ថភាពកម្ពុជា ក្នុងការតបតនឹងហានិភ័យនៃសន្តិសុខបច្ចេកវិទ្យាព័ត៌មាន ក្នុងសម័យកាលនៃបដិវត្តន៍ឧស្សាហកម្មទី៤។

**<u>ការងារចុងក្រោយ គឺការលើកកម្ពស់គុណភាព ប្រសិទ្ធិភាពការងារ និងការអភិវឌ្ឍសមត្ថភាពមន្ត្រីការទូត</u>**

ក្នុងឱកាសបិទសន្និបាតក្រសួងកាលពីឆ្នាំទៅមិញ ខ្ញុំក៏បានផ្តល់អនុសាសន៍មួយចំនួន ដើម្បីដោះស្រាយបញ្ហាប្រឈមស្តីពីធនធានមនុស្សដែលក្រសួងការបរទេស ក៏ដូចជាក្រសួងស្ថាប័នរដ្ឋនានាជួបប្រទះដែរ។

ខ្ញុំមានសេចក្តីរីករាយ ចំពោះផ្លែផ្កាដែលក្រសួងសម្រេចបានក្នុងការកែទម្រង់ផ្ទៃក្នុង តាមរយៈនៃការបញ្ចូលប្រព័ន្ធគុណាធិបតេយ្យនៅក្នុងការតែងតាំង និងតំឡើងតួនាទី និងការកសាងសមត្ថភាពជំនាញវិជ្ជាជីវៈ ដែលប៉ុន្មានឆ្នាំចុងក្រោយនេះ មានការលើកកម្ពស់គួរឱ្យកត់សំគាល់។ វិទ្យាស្ថានការទូតនិងទំនាក់ទំនងអន្តរជាតិ ដែលត្រូវបានបង្កើតនិងដាក់ឱ្យដំណើរការ ២ឆ្នាំមុននេះ បានរួមចំណែកយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាល បំពាក់បំប៉នចំណេះដឹង និងសមត្ថភាពវិភាគដល់មន្ត្រីការទូតយើង។ ពិតហើយការបណ្តុះបណ្តាលធនធានមនុស្ស គឺជាការវិនិយោគដែលប្រើពេលយូរ មុននឹងបានទទួលផល។ ហេតុនេះ ខ្ញុំសូមលើកទឹកចិត្តថ្នាក់ដឹកនាំក្រសួង មន្ត្រីការទូតយើងទាំងអស់បន្តប្រឹងប្រែងបង្កើនចំណេះដឹង លើកកម្ពស់សមត្ថភាពវិភាគស្រាវជ្រាវព័ត៌មាន ពិសេសពាក់ព័ន្ធនឹងភូមិសាស្ត្រ-នយោបាយ ភូមិសាស្ត្រ-យុទ្ធសាស្ត្រ និងភូមិសាស្ត្រ-សេដ្ឋកិច្ច។

ខ្ញុំក៏សូមឆ្លៀតឱកាសនេះ ដើម្បីអរគុណប្រទេសជាមិត្តនានាដែលបានផ្តល់ជំនួយ និងកិច្ចសហប្រតិបត្តិការល្អ ក្នុងការជួយអភិវឌ្ឍធនធានមនុស្ស តាមរយៈអាហារូបករណ៍ ទស្សនកិច្ចសិក្សា ការផ្លាស់ប្តូរបទពិសោធន៍ ការរៀបចំវគ្គបណ្តុះបណ្តាល ក៏ដូចជាការផ្តល់បាឋកថា ចែករំលែកចំណេះដឹង និងទស្សនទាននានា។ លុះត្រាណាតែជួរអ្នកការទូតរបស់យើងមានសមត្ថភាព វិជ្ជាជីវៈខ្ពស់ រៀងវៃ ប្រកបដោយគំនិតយុទ្ធសាស្ត្រ និងស្មោះត្រង់ចំពោះជាតិមាតុភូមិ ទើបយើងនឹងអាចសម្រេចបានដោយជោគជ័យនូវបេសកកម្មលើកស្ទួយ និងការពារផលប្រយោជន៍គោលរបស់ប្រទេសជាតិយើងបាន។ ក្នុងស្មារតីនេះ ខ្ញុំតែងតែគាំទ្រនូវគំនិតផ្តួចផ្តើមនានារបស់ក្រសួងការបរទេស ក្នុងការបង្កើនមធ្យោបាយបច្ចេកទេស ហិរញ្ញវត្ថុ និងធនធានមនុស្ស ដើម្បីបំរើផលប្រយោជន៍របស់ប្រទេសជាតិ។

ខ្ញុំសូមលើកសរសើរជាថ្មីម្តងទៀតចំពោះកិច្ចប្រឹងប្រែង និងលទ្ធផលល្អប្រសើររបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងចំពោះការខិតខំ និងឆន្ទៈខ្ពស់របស់មន្ត្រីការទូតរបស់យើង ក្នុងការបំរើជាតិមាតុភូមិ និងសូមជូនពរឱ្យទទួលបានជោគជ័យថ្មីៗ ថែមទៀត។

*(អង្គសន្និបាតទះដៃរួចទើបសូមសម្តេចបន្ត)*

ឆ្នាំ២០២០នេះ ជាឆ្នាំដែលអង្គការសហប្រជាជាតិប្រារព្ធខួបទី៧៥របស់ខ្លួន ក្រោមការប្តេជ្ញារួមគ្នា ដើម្បីពង្រឹងលើកតម្កើងពហុភាគីនិយម។

ឆ្នាំ២០២០នេះ ក៏ជាឆ្នាំដែលកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី១៣ (ASEM13) ក្រោមប្រធានបទ "ពង្រឹងពហុភាគីនិយមដើម្បីកំណើនរួម"។

ចាប់តាំងពីកម្ពុជាបានក្លាយជាសមាជិកASEM នៅឆ្នាំ២០០៤មក យើងតែងផ្តល់តំលៃដល់វេទិកានេះ ជាវេទិកាដ៏សំខាន់សំរាប់កិច្ចសហប្រតិបត្តិការរវាងតំបន់អាស៊ីនិងអឺរ៉ុប ដែលនាំមកនូវផលប្រយោជន៍ទៅវិញទៅមកជាច្រើន។

សព្វថ្ងៃនេះ គ្មាននរណាអាចប្រកែកបានឡើយចំពោះតំលៃ និងសារៈសំខាន់នៃវេទិកាASEM នៅក្នុងកិច្ចការនយោបាយ ការទូត និងទំនាក់ទំនងអន្តរតំបន់។ ចាប់តាំងពីការកកើតឡើងរបស់ខ្លួននាឆ្នាំ១៩៩៦ ASEM បានបំពេញតួនាទីជាគន្លឹះក្នុងឋានៈជាវេទិកាសន្ទនា និងសហប្រតិបត្តិការដែលផ្សារភ្ជាប់អាស៊ីនិងអឺរ៉ុប។

ASEM ក៏ជាវេទិកាដែលផ្តល់ឱ្យកម្ពុជានូវកាលានុវត្តភាពជាច្រើន ដើម្បីជំរុញឱ្យកាន់តែរហ័ស និងស៊ីជម្រៅនូវសមាហរណកម្មរបស់ខ្លួននៅក្នុងតំបន់ និងពិភពលោកផងដែរ។

កិច្ចប្រជុំកំពូល ASEM លើកទី១៣ខាងមុខនេះ គឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនិងការទូតធំបំផុតសម្រាប់កម្ពុជាយើង។ ការធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលនេះ គឺជាឱកាសដ៏ប្រសើរបំផុតសម្រាប់កម្ពុជា បញ្ជាក់ក្នុងកំរិតខ្ពស់បំផុតនូវការប្តេជ្ញារបស់ខ្លួន ចំពោះការពង្រឹងប្រព័ន្ធពហុភាគីនិយម ការចូលរួមក្នុងកិច្ចប្រឹងប្រែងរបស់ពិភពលោក ក្នុងការដោះស្រាយការប្រឈមជាសកល និងការចូលរួមស្វែងរកកាលានុវតភាពក្នុងការធ្វើឱ្យប្រសើរនូវសេដ្ឋកិច្ចពិភពលោក។

ការធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំដែលនឹងប្រមូលផ្តុំមេដឹកនាំពី៥១ប្រទេស និងប្រធានស្ថាប័នតំបន់២ ព្រមជាមួយការចាត់តាំងរៀបចំព្រឹត្តិការណ៍ចំនួន៧ទៀតនោះ គឺទាមទារកិច្ចប្រឹងប្រែងថ្នាក់ជាតិ ដើម្បីដោះស្រាយបញ្ហាភស្តុភារ ហិរញ្ញវត្ថុ បច្ចេកទេស ទីតាំង ពិធីការ និងការធានាសន្តិសុខខ្ពស់បំផុត។ កម្ពុជាប្តេជ្ញានឹងសម្រេចកិច្ចការនេះប្រកបដោយកិត្តិយស និងជោគជ័យ។

ក្នុងឱកាសដ៏មហោឡារិកនេះ ខ្ញុំមានសេចក្តីរីករាយ និងកិត្តិយស សូមប្រកាសជាផ្លូវការ នូវការទទួលធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប លើកទី១៣ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៦ និង១៧ ខែវិច្ឆិកា ឆ្នាំ២០២០ នៅរាជធានីភ្នំពេញ។

*(សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន)*